(០៥)

# ប្រកាសស្តីពី
# ការបង្កើតអង្គភាពអមខុទ្ទកាល័យ
# ឯកឧត្តមរដ្ឋមន្ត្រី

លេខ: ១៦៨ ប្រក.កសក

ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៦៨ ប្រក. កសក

ប្រកាស

ស្តីពី

ការបង្កើតអង្គភាពអមខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បេឡាដ្ឋានគណនេយ្យហិរញ្ញវត្ថុ
ដល់ថ្ងៃទី ០៧ ខែ ... ឆ្នាំ២០១...
លេខ ... 
ម៉ោង ...

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

ប្រការ១.

បង្កើតអង្គភាពអមខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីជាសេនាធិការ សម្រាប់បញ្ជូនបទបញ្ជាឯកឧត្តមរដ្ឋមន្ត្រី និងតាមដានសម្របសម្រួលការអនុវត្តការងារសំដៅធ្វើឲ្យមានអភិបាលកិច្ចល្អតាមអង្គភាពក្រោមឱវាទក្រសួង។

ប្រការ២.

អង្គភាពអមខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីមាន៖

ក-អង្គភាពត្រួតពិនិត្យតាមដានការអនុវត្តការងារផ្ទៃក្នុង

ខ-អង្គភាពត្រួតពិនិត្យតាមដានការអនុវត្តគម្រោងអភិវឌ្ឍន៍

គ-អង្គភាពត្រួតពិនិត្យតាមដានការអនុវត្តគម្រោងវិនិយោគ។

ប្រការ៣._

អង្គភាពត្រួតពិនិត្យតាមដានការអនុវត្តការងារផ្ទៃក្នុង មានភារកិច្ច៖

- ជំរុញលើកទឹកចិត្តមន្ត្រីរាជការទាំងអស់ក្នុងក្រសួងឱ្យប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ សីលធម៌ស្អាតស្អំ មនសិការវិជ្ជាជីវៈ និងអនុវត្តឱ្យមានប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវតាមការប្រគល់ភារកិច្ចជូន និងជៀសវាងទំនាស់ក្នុងការងារ
- ជំរុញបង្កើនការរៀបចំ និងអនុវត្តវិធានផ្ទៃក្នុងបន្ថែមលើច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដូចជាការកសាងផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិផ្សេងៗទៀត ដើម្បីកសាងស្ថាប័នឲ្យបានស្អាតស្អំ និងជាគំរូក្នុងការគ្រប់គ្រងការងារឱ្យបានជោគជ័យ និងប្រសិទ្ធភាព
- ជំរុញកសាងហេដ្ឋារចនាសម្ព័ន្ធរឹងខ្វងសម្រាប់វិស័យបច្ចេកវិទ្យាព័ត៌មាន ធ្វើទំនើបកម្មប្រព័ន្ធរដ្ឋបាល និងមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យអេឡិចត្រូនិច ព្រមជាមួយនិងការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យានេះ
- ជំរុញពង្រឹងការតាមដានត្រួតពិនិត្យ និងសម្របសម្រួលការអនុវត្តការងារ និងការគ្រប់គ្រងរបស់អង្គភាពក្រោមឱវាទក្រសួង សំដៅឆ្ពោះទៅពង្រឹងសមត្ថភាពស្ថាប័ន ពង្រឹងការអនុវត្តច្បាប់ដើម្បីសម្រេចបាននូវភាពត្រឹមត្រូវតាមគោលការណ៍ និងលក្ខខណ្ឌកំណត់ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព
- ទទួលអនុវត្តការងារផ្សេងៗទៀតតាមការណែនាំផ្ទាល់ដែលឯកឧត្តមរដ្ឋមន្ត្រីប្រគល់ជូន។

ប្រការ៤._

អង្គភាពត្រួតពិនិត្យតាមដានការអនុវត្តគម្រោងអភិវឌ្ឍន៍មានភារកិច្ច៖

- ជំរុញការពង្រឹងភាពជាដៃគូទូលំទូលាយជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដើម្បីប្រមូលធនធានហិរញ្ញប្បទានពីគ្រប់ប្រភពសម្រាប់លើកស្ទួយវិស័យកសិកម្ម ព្រៃឈើ និងជលផល ដោយឈរលើគោលការណ៍នៃភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល តាមរយៈការពង្រឹងការតាមដានត្រួតពិនិត្យ សម្របសម្រួល និងជំរុញការអនុវត្ត និងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ដើម្បីធានាការអនុវត្តត្រឹមត្រូវ មាននិរន្តភាព ស្របតាមគោលការណ៍ លក្ខខណ្ឌកំណត់ និងមានអភិបាលកិច្ចល្អ
- ទទួលអនុវត្តការងារផ្សេងៗទៀតតាមការណែនាំផ្ទាល់ដែលឯកឧត្តមរដ្ឋមន្ត្រីប្រគល់ជូន។

ប្រការ៥._

អង្គភាពត្រួតពិនិត្យតាមដានការអនុវត្តគម្រោងវិនិយោគមានភារកិច្ច៖

- ជំរុញអភិវឌ្ឍវិស័យឯកជនឱ្យកាន់តែមានភាពរស់រវើក និងមានជវភាពខ្លាំងថែមទៀតក្នុងតួនាទីជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និងជំរុញការប្រែក្លាយកម្ពុជាឱ្យទៅជាគោលដៅវិនិយោគប្រកបដោយភាពទាក់ទាញ និងប្រកួតប្រជែងនៅក្នុងតំបន់ ពិសេសក្នុងក្របខណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន តាមរយៈការពង្រឹងការតាមដាន ត្រួតពិនិត្យ សម្របសម្រួល និងជំរុញការអនុវត្តនិងការគ្រប់គ្រងគម្រោងវិនិយោគ ដើម្បីធានាការអនុវត្តត្រឹមត្រូវតាមគោលការណ៍ លក្ខខណ្ឌកំណត់ និងមានអភិបាលកិច្ចល្អ
- ទទួលអនុវត្តការងារផ្សេងៗទៀតតាមការណែនាំផ្ទាល់ដែលឯកឧត្តមរដ្ឋមន្ត្រីប្រគល់ជូន។

ប្រការ៦._

សមាសភាពក្រុមការងារដឹកនាំអង្គភាពអមខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រការ៧.-

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បណ្ឌិត អ៊ុក រ៉ាប៊ុន

កន្លែងទទួល៖

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - "ដើម្បីជូនជ្រាប"
- -ដូចប្រការ៧
  - "ដើម្បីអនុវត្ត"
- -ឯកសារ កាលប្បវត្តិ